**ក្រុមប្រឹក្សាបង្កើតកម្លាំងពលកម្មរបស់ Pacific Gateway – ការកែសំរួលផែនការថ្នាក់មូលដ្ឋាន**

**វេទិកាសហគមន៍ ស្ដីពីសេវាការងារថ្នាក់មូលដ្ឋាន**

ទីតាំង ៖ ទីកន្លែងការងារ (The WorkPlace)

ផ្លូវលេខ 4811 Airport Plaza Drive

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា CA 90815

កាលបរិច្ឆេទ ៖ ថ្ងៃទី 5 ខែធ្នូ ឆ្នាំ 2018

ពេលវេលា ៖ 10:00 ព្រឹក – 12:00 ថ្ងៃត្រង់

**<u>បញ្ហាខ្លឹមសារសម្រាប់កិច្ចប្រជុំពិភាក្សា</u>**

**តើមានសហគមន៍ណាខ្លះដែលត្រូវការ សេវាច្រកផ្លូវប៉ាស៊ីហ្វិកច្រើនជាងគេបំផុត?**

- សហគមន៍ជនពិការ - ប្រជាពលរដ្ឋ ដែលទទួលបានសេវា មិនគ្រប់គ្រាន់, ដែលមានសមត្ថភាពបំពេញការងារ នៅក្នុងសហគមន៍
- សហគមន៍និយាយភាសាអេស្ប៉ាញ/អាមេរិកខាងត្បូង – សហគមន៍ ដែលមានចំណូល ទាបបំផុត
- សហគមន៍ខ្មែរ – ត្រូវការសេវាបកប្រែ, ឧបសគ្គផ្នែកភាសា
- អ្នកចូលនិវត្តន៍/ពលករវ័យចំណាស់ – បទពិសោធន៍អាចប្រើប្រាស់បានសម្រាប់ការងារ និងចែករំលែកជាមួយអ្នកផ្សេងទៀត ។
- ប៉ែកខាងលិច និងខាងជើង ឡុងប៊ិច - ប្រជាពលរដ្ឋ ដែលមានចំណូលទាប, មានបញ្ហាប្រឈម ក្នុងការទទួលបានសេវានានា នៅផ្នែកខាងនោះនៃទីក្រុង, ត្រូវការ ការិយាល័យរណប, មានបញ្ហាផ្នែកមធ្យោបាយធ្វើដំណើរ (ខ្សែរថយន្តក្រុង) និង ក្រុមដើងកាង។
- ពលរដ្ឋអាមេរិក ដើមកំណើតអាហ្វ្រិក – ចំណូលទាប, គ្មានការងារធ្វើ
- យុវជននៅទំនេរ – និស្សិតវិទ្យាល័យ នៅចន្លោះពេល រវាងសាលារៀន និងការងារ, គ្មានការងារធ្វើ ឬមានការងារតិចតួច
- យុវជន - ខ្វះ ជំនាញទន់ និងជំនាញវិជ្ជាជីវៈ
- តំបន់កណ្ដាល ឡុងប៊ិច – ស្ត្រីជាម្ដាយទោល ជាមេគ្រួសារដែលត្រូវការ សេវានានា, ការថែទាំកុមារ និងជំនាញទន់ ។ ត្រូវការ ឱ្យមានការយកចិត្តទុកដាក់ ។
- លើកទឹកចិត្ត អង្គការសហគមន៍ (CBOs) ឱ្យសហការ និងធ្វើការជាមួយគ្នាយ៉ាងជិតស្និទ
- ជំនួយបច្ចេកទេស ដល់អង្គការសាសនា (FBOs) និង CBOs ។ រត់រកគ្នាដើម្បីទទួលបានជំនួយ និងធនធាន ។
- វគ្គបណ្ដុះបណ្ដាល ស្ដីពីភាពរសើប ផ្នែកវប្បធម៌ ដែលឆ្លុះបញ្ចាំង ពីសហគមន៍ ។
- កិច្ចសហការ កាន់តែរឹងមាំ រវាង ច្រកផ្លូវប៉ាស៊ីហ្វិក និង CBOs ។ CBOs មានការទុកចិត្តពីនរសនជន នានា ។
- ត្រូវការ ការិយាល័យរណប ដើម្បីកាត់បន្ថយ បញ្ហាមធ្យោបាយធ្វើដំណើរ - ទីតាំងរណប នៅតំបន់ប៉ែកខាងជើង, កណ្ដាល និងខាងលិចឡុងប៊ិច - ផ្ដល់ សិទ្ធិអំណាច ដល់អង្គការនានា ដើម្បីធ្វើជាដៃគូ ក្នុងការផ្ដល់ទីកន្លែងសម្រាប់សម្រួលកម្មវិធីនានា ។

- មានសារៈសំខាន់ ក្នុងការធ្វើការជាមួយអង្គការសាសនា។ ទំនាក់ទំនង ផ្នែកសាសនា ទៅនឹង សេវាកម្លាំងពលកម្ម។ មានភាពជឿជាក់ និងផាសុខភាពកាន់តែប្រសើរឡើង។ ទំនាក់ទំនង និយោជកតាមរយៈអង្គការទាំងនេះ នៅតាមការជួបជុំនានា ។
- ការកសាង លទ្ធភាពទទួលបាន នៅក្នុងសហគមន៍ ដែលបុគ្គលម្នាក់ៗ មានអារម្មណ៍ ជឿជាក់ និងផាសុខភាព។
- ការចាំបាច់ ក្នុងការចូលទៅតាមសហគមន៍នានា, ទំនាក់ទំនងដើម្បីជួបជាមួយ ប្រជាពលរដ្ឋនៅតាមទីលំនៅ របស់ពួកគេ។

**តើមាន កម្មវិធីកម្លាំងពលកម្ម ឬប្រតិបត្តិល្អបំផុតអ្វីខ្លះដែលលោកអ្នកចង់ឱ្យមាន នៅឡូងប៊ិច /តំបន់ស៊ីណល?**

- ត្រូវការសេវា កាន់តែច្រើនថែមទៀត សម្រាប់ប្រជាពលរដ្ឋ ស្ថិតក្នុងដំណាក់កាល ផ្លាស់ទីពីទណ្ឌិតទៅរកការងារ (P2E)
  - បង្កើនកម្រិតសេវាដែលមានស្រាប់ឱ្យបានកាន់តែប្រសើរឡើង
  - លើកបង្ហាញពីសេវាដែលអាចរកបាន
- ភាពជាដៃគូ និង ការចូលរួម កាន់តែរឹងមាំឡើង ជាមួយ ផ្នែកសាកល្បងការងារ
- ភ្ជាប់ទំនាក់ទំនង ជាមួយបុគ្គលម្នាក់ៗ មុនពេលពួកគេ ត្រូវបានដោះលែង, ដោយត្រូវការធនធានបន្ថែមទៀត ដើម្បីជួយ ក្នុងអន្តរកាល
- L.A.M.P – យុវជនដែលមានទេពកោសល្យកម្រិតមធ្យម ។ កម្មសិក្សាការងារឱ្យបានច្រើនបន្ថែមទៀត និងការលើកកម្ពស់កម្មវិធីនានា
- កម្មវិធី ជាមួយក្មេងជំទង់ឱ្យបានច្រើនបន្ថែមទៀត។ កម្មវិធីបង្ការ, គ្រូណែនាំខណៈដែលពួកគេស្ថិតនៅក្នុងប្រព័ន្ធ។
- ការធ្វើឱ្យប្រសើរឡើងនៃមជ្ឈមណ្ឌលយុវជន នៅតំបន់ប៉ែកខាងលិច/តំបន់កណ្ដាល
- កម្មវិធីចូលម្ដងទៀត សម្រាប់យុវជនដែលត្រឡប់មកវិញ
- ឧបករណ៍វាយតម្លៃវគ្គបណ្ដុះបណ្ដាលដើម្បីជួយបង្ការ មិនឱ្យធ្លាក់ខ្លួនប្រព្រឹត្តខុសម្ដងទៀត
  - ការវាយតម្លៃហានិភ័យ Ohio –
  - ការព្យាបាលផ្នែកការទទួលស្គាល់សីលធម៌ (MRT)
  - ការវាយតម្លៃហានិភ័យ
  - វគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងសារពើភ័ណ្ឌផ្ទាល់ខ្លួន
- កិច្ចសហការជាមួយ CBOs & FBO ដែលមានការទុកចិត្តដើម្បីបង្កើតសេវាគាំទ្រ និង សេចក្ដីត្រូវការលើការបណ្ដុះបណ្ដាល
- កម្មវិធីបង្រៀនបុរសវ័យក្មេង ធ្វើជាឪពុកនិងបញ្ចប់ វដ្ដភាពក្រីក្រតជំនាន់ "តួនាទីបុរស"
- ត្រូវការវិធីសាស្ត្រ លក្ខណៈគ្រប់ជ្រុងជ្រោយ, ដោយយល់ដឹង អំពីកម្មវិធីនានា ដែលមានរួចហើយ, ការលើកកម្ពស់កម្មវិធីនានា ឱ្យកាន់តែប្រសើរឡើង, ការចែករំលែក ប្រតិបត្តិល្អបំផុត

**តើច្រកផ្លូវប៉ាស៊ីហ្វិកអាចគាំទ្រដល់កម្មវិធីកម្លាំងពលកម្មនៅមូលដ្ឋាន ដោយរបៀបណាដែរ ?**

- ពង្រឹងទំនាក់ទំនង ជាមួយ CBOs ដើម្បីបង្កើតកម្មវិធីនានា – កម្មវិធីជំនួយភាសា, សេវាបកប្រែ ។
- CBOS មានបញ្ហាប្រឈម ចំពោះមុខងាររដ្ឋបាល ។ ត្រូវការឱ្យមានជំនួយបច្ចេកទេស, ដំណើរការបញ្ញាបធ្វើអោយប្រសើរឡើងនានា ។
- ការអប់រំសហគមន៍ អំពីសេវា និងកម្មវិធី របស់យើង ព្រមទាំង របៀបទទួលបាន ។
- ធ្វើការ ជាមួយ CBOs ដើម្បីបំពេញឱ្យបាន តាមតារាងវាស់ភាពជោគជ័យ, ការទូទាត់ តាមសមត្ថភាពបំពេញការងារ

- សហការ លក្ខណៈរដ្ឋបាល ដើម្បីលុបបំបាត់ ដែនកម្រិតមូលនិធិ និង ដំណើរការពិបាក នានា ។
- ច្រកផ្លូវប៉ាស៊ីហ្វិក ទាញប្រយោជន៍ ពីមូលនិធិនានាដើម្បីផ្តល់ថវិកាដល់ CBOs, FBOs – ដើរតួជាប្រភពបង្គរមូលនិធិ
- សហការជាមួយ CBOs និង FBOS សម្រាប់ឱកាសទទួលបានមូលនិធិនានា ។
- ឱកាសការងារ និងការអភិវឌ្ឍន៍ការងារសម្រាប់មនុស្សវ័យចាស់ ។ ចំណូលបន្ថែម សម្រាប់អ្នកដែលមានចំណូលថេរ ។
- សេវាអាហារ និងការដឹកជញ្ជូន (អាហារក្តៅ) ។